**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ:** ១៦ . អនក្រ. បក

# អនុក្រឹត្យ
# ស្តីពី
# ការរៀបចំ និងការប្រព្រឹត្តទៅ របស់សភាពាណិជ្ជកម្មកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការបញ្ចប់មុខងារ និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៥/០៣ ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសភាពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០៦/០២២ ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា២ និងមាត្រា១៥ នៃច្បាប់ស្តីពីសភាពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ១៣១ អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

## សម្រេច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះមានគោលដៅកំណត់ការរៀបចំ និងការប្រព្រឹត្តទៅរបស់សភាពាណិជ្ជកម្មកម្ពុជា។

## ជំពូកទី ២
## តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធរបស់សភាពាណិជ្ជកម្មកម្ពុជា

**មាត្រា ២ .-**

សភាពាណិជ្ជកម្មរាជធានី-ខេត្ត ប្រមូលផ្តុំបង្កើតសភាពាណិជ្ជកម្មកម្ពុជា។

សភាពាណិជ្ជកម្មកម្ពុជា ធ្វើសកម្មភាពទូទាំងព្រះរាជាណាចក្រកម្ពុជា ហើយគាំទ្រដល់ជំហរ និងសកម្មភាពរបស់សភាពាណិជ្ជកម្មរាជធានី-ខេត្តទាំងឡាយ។ សភាពាណិជ្ជកម្មកម្ពុជា ទទួលបន្ទុកគ្រប់គ្រងសេវាដែលទាក់ទងដល់ពាណិជ្ជកម្ម ឧស្សាហកម្ម សិប្បកម្ម កសិកម្ម និងអាជីវកម្មផ្សេងទៀត ដែលហួសពីលទ្ធភាពរបស់សភាពាណិជ្ជកម្មរាជធានី-ខេត្ត។

សភាពាណិជ្ជកម្មកម្ពុជា អាចស្នើសុំបើកការិយាល័យតំណាងសភាពាណិជ្ជកម្មកម្ពុជា នៅរាជធានី-ខេត្ត ឬតំបន់នៃប្រទេសណាមួយ ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម។

ការទទួលស្គាល់សមាសភាពនៃការិយាល័យតំណាងសភាពាណិជ្ជកម្មកម្ពុជា នៅរាជធានី-ខេត្ត ឬតំបន់នៃប្រទេសណាមួយ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម។

ការរៀបចំ និងការប្រព្រឹត្តទៅ នៃការិយាល័យតំណាង ព្រមទាំងវិធាន និងនីតិវិធី នៃការជ្រើសរើសសមាសភាពនៃការិយាល័យតំណាងសភាពាណិជ្ជកម្មកម្ពុជានៅក្រៅប្រទេស ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម។

**មាត្រា ៣.-**

ភារកិច្ចសភាពាណិជ្ជកម្មកម្ពុជា រួមមាន :

- ធ្វើទំនាក់ទំនងជាមួយសភាពាណិជ្ជកម្មរាជធានី-ខេត្ត និងជួយសម្របសម្រួលការងារ ធ្វើឱ្យមានការអភិវឌ្ឍ
- ចូលរួមអនុវត្តគោលនយោបាយសេដ្ឋកិច្ចពាណិជ្ជកម្មរបស់រាជរដ្ឋាភិបាល ដើម្បីបង្កើនសកម្មភាពសេដ្ឋកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា
- ផ្តល់ជូនរាជរដ្ឋាភិបាលនូវយោបល់ និងព័ត៌មានស្តីពី សេដ្ឋកិច្ច និងវិនិយោគ
- ជាដៃគូចរចាជាមួយរាជរដ្ឋាភិបាល ក្នុងនាមតំណាងសហគមន៍ ពាណិជ្ជកម្ម-ឧស្សាហកម្ម សិប្បកម្ម-កសិកម្ម និងសេវាកម្ម
- ធ្វើទំនាក់ទំនងជាមួយប្រភពសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្រៅប្រទេស
- បំពេញភារកិច្ចដែលហួសពីសមត្ថភាព និងលទ្ធភាពរបស់សភាពាណិជ្ជកម្មរាជធានី-ខេត្ត
- ជាសភាប្រឹក្សាធុរកិច្ចយុទ្ធសាស្ត្រសហប្រតិបត្តិការសេដ្ឋកិច្ច អាយ៉េយ៉ាវ៉ាឌី ចាវប្រាយ៉ា មេគង្គ (ACMECS)

- សម្របសម្រួលសភាពាណិជ្ជកម្មរាជធានី-ខេត្តឱ្យធ្វើសហប្រតិបត្តិការជាមួយគ្នា ដើម្បីប្រើប្រាស់សក្តានុពលដែលមាននៅតាមរាជធានី-ខេត្ត
- ចូលរួមសកម្មភាពជាមួយសភាពាណិជ្ជកម្មក្នុងតំបន់ និងលើសកលលោក
- បង្កើត និងគ្រប់គ្រង គ្រឹះស្ថានធ្វើអាជីវកម្ម និងគ្រឹះស្ថានបណ្តុះបណ្តាលវិជ្ជាជីវៈ
- ចូលរួមក្នុងការដេញថ្លៃជាសាធារណៈ ដើម្បីទទួលបានភារកិច្ចជាសម្បទានិកនៃសំណង់សាធារណៈ ឬទទួលបន្ទុកធ្វើសេវាសាធារណៈ
- ធ្វើរបាយការណ៍ប្រចាំឆ្នាំ ពីសកម្មភាពរបស់ខ្លួន ជូនរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម។

**មាត្រា ៤.–**

សភាពាណិជ្ជកម្មកម្ពុជាស្ថិតនៅក្រោមអាណាព្យាបាលនៃក្រសួងពាណិជ្ជកម្ម ហើយមានទីស្នាក់ការនៅរាជធានីភ្នំពេញ។

**មាត្រា ៥.–**

សភាពាណិជ្ជកម្មកម្ពុជាត្រូវបានតំណាងដោយប្រធានរបស់សភាពាណិជ្ជកម្មរាជធានី-ខេត្ត នីមួយៗ។

**មាត្រា ៦.–**

សមាជិកសភាពាណិជ្ជកម្មកម្ពុជា មានអាណត្តិ ៣ (បី) ឆ្នាំ ហើយត្រូវជ្រើសតាំងសារជាថ្មី នៅក្រោយពេលបោះឆ្នោតជ្រើសតាំងសភាពាណិជ្ជកម្មរាជធានី-ខេត្ត នីមួយៗ រាល់ ៣ (បី) ឆ្នាំម្តង។

សមាជិកសភាពាណិជ្ជកម្មកម្ពុជា ត្រូវជ្រើសតាំងបង្គ្រប់នៅពេលមានកន្លែងទំនេរ ស្របតាមមាត្រា ៥ នៃអនុក្រឹត្យនេះ។

**មាត្រា ៧.–**

៣០ ថ្ងៃយ៉ាងយូរ ក្រោយពេលបោះឆ្នោតប្រចាំឆ្នាំ ៣ ឆ្នាំម្តង សភាពាណិជ្ជកម្មរាជធានី-ខេត្តនីមួយៗ ត្រូវចាត់តាំងតំណាងរបស់ខ្លួន ឱ្យធ្វើជាសមាជិកសភាពាណិជ្ជកម្មកម្ពុជា។

**មាត្រា ៨.–**

សភាពាណិជ្ជកម្មកម្ពុជា បំពេញមុខការរបស់ខ្លួនដោយមិនយកប្រាក់បៀវត្សរ៍ ឬប្រាក់បំណាច់អ្វីឡើយ។

**មាត្រា ៩.–**

សភាពាណិជ្ជកម្មកម្ពុជា ត្រូវគ្រប់គ្រងដោយការិយាល័យប្រតិបត្តិ ដែលមានសមាសភាពដូចខាងក្រោម÷

- ប្រធានសភាពាណិជ្ជកម្មកម្ពុជា ជាប្រធាន
- ប្រធានសភាពាណិជ្ជកម្មរាជធានី-ខេត្តទាំងអស់ ជាអនុប្រធាន
- សមាជិកជ្រើសតាំងនៃសភាពាណិជ្ជកម្មរាជធានី-ខេត្ត មួយចំនួន ជាអនុប្រធាន
- សមាជិកជ្រើសតាំងនៃសភាពាណិជ្ជកម្មរាជធានី-ខេត្ត មួយរូប ជាហិរញ្ញិក
- សមាជិកជ្រើសតាំងនៃសភាពាណិជ្ជកម្មរាជធានី-ខេត្ត មួយរូប ជាលេខាធិការ។

**មាត្រា ១០.–**

ប្រធានសភាពាណិជ្ជកម្មកម្ពុជាត្រូវបានជ្រើសរើសក្នុងចំណោមប្រធានសភារាជធានី-ខេត្ត តាមរយៈការបោះឆ្នោតដោយប្រធានសភាពាណិជ្ជកម្មរាជធានី-ខេត្ត។

ការបោះឆ្នោតជ្រើសរើសប្រធានត្រូវធ្វើជាពីរជុំ ដោយយកតាមសំឡេងភាគច្រើនដាច់ខាត។ ក្នុងករណីមានសំឡេងស្មើគ្នា ត្រូវជ្រើសរើសអ្នកមានអាយុច្រើនជាង។

ចំពោះហិរញ្ញិក និងលេខាធិការ ការបោះឆ្នោតធ្វើតែមួយជុំ ដោយយកតាមសំឡេងភាគច្រើនធម្មតា។

ប្រធានសភាពាណិជ្ជកម្មកម្ពុជា អាចជ្រើសរើសអនុប្រធានមួយចំនួនថែមទៀត តាមការចាំបាច់ពីក្នុងចំណោមអនុប្រធានឬសមាជិកជ្រើសតាំងសភាពាណិជ្ជកម្មរាជធានី-ខេត្ត សម្រាប់ជួយការងារនៅក្នុងសភាពាណិជ្ជកម្មកម្ពុជា។

**មាត្រា ១១.–**

ប្រធានសភាពាណិជ្ជកម្មកម្ពុជាជាប្រធានការិយាល័យប្រតិបត្តិមានភារកិច្ចដឹកនាំសភាពាណិជ្ជកម្មកម្ពុជា និងតំណាងឱ្យសភាពាណិជ្ជកម្មកម្ពុជាចំពោះមុខអាជ្ញាធរ និងក្នុងរាល់សកម្មភាពសង្គម។

ប្រធានត្រូវដឹកនាំរាល់ការប្រជុំ។ ក្នុងករណីអវត្តមាន ប្រធានត្រូវចាត់តាំងអនុប្រធានម្នាក់ជំនួស។ ប្រធានសភាពាណិជ្ជកម្ម មានអាណត្តិ ៣ ឆ្នាំ។

**មាត្រា ១២.–**

ប្រធានសភាពាណិជ្ជកម្មរាជធានី-ខេត្តទាំងអស់ប្រជុំគ្នា ធ្វើការបោះឆ្នោតជ្រើសតាំងសមាសភាពការិយាល័យប្រតិបត្តិសភាពាណិជ្ជកម្មកម្ពុជា។ ការបោះឆ្នោតត្រូវរៀបចំដោយគណៈកម្មការមួយ ដែលមានសមាជិក ២ រូប÷

- ប្រធាន ជ្រើសរើសយកសមាជិកដែលមានអាយុច្រើនជាងគេ
- សមាជិក និងជាលេខាធិការ ជ្រើសរើសយកសមាជិកដែលមានអាយុតិចជាងគេ។

ការបោះឆ្នោតត្រូវមានតំណាងក្រសួងពាណិជ្ជកម្ម ចូលរួម។

សមាជិកភាពការិយាល័យប្រតិបត្តិសភាពាណិជ្ជកម្មកម្ពុជា ត្រូវទទួលស្គាល់ដោយអនុក្រឹត្យ។

**មាត្រា ១៣.–**

សភាពាណិជ្ជកម្មកម្ពុជា ត្រូវបង្កើតអគ្គនាយកដ្ឋានមួយ ដើម្បីទទួលបន្ទុកគ្រប់គ្រងការងារប្រចាំថ្ងៃ។

**មាត្រា ១៤.–**

ការបង្កើត និងការប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋាន និងគណៈកម្មការផ្សេងៗទៀត ត្រូវកំណត់ដោយបទបញ្ជាផ្ទៃក្នុង។

## ជំពូកទី ៣
## របៀបរបបធ្វើការងាររបស់សភាពាណិជ្ជកម្មកម្ពុជា

**មាត្រា ១៥.–**

សមាជិកសភាពាណិជ្ជកម្មកម្ពុជាធ្វើការរួមប្រជុំសន្និបាត ៤ ដងក្នុងមួយឆ្នាំ ឬលើសពីនេះតាមការចាំបាច់តាមសំណើរបស់ប្រធាន ឬតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ឬតាមសំណើមួយភាគបីនៃចំនួនសមាជិករបស់សភាពាណិជ្ជកម្ម កម្ពុជា។

**មាត្រា ១៦.–**

ការប្រជុំសន្និបាតអាចប្រព្រឹត្តទៅបានលុះត្រាតែ មានសមាជិកយ៉ាងតិច ២ ភាគ ៣ ចូលរួម។ ក្នុងករណីដែលកូរ៉ុមនេះមិនគ្រប់គ្រាន់ទេ ប្រធានត្រូវកោះប្រជុំសារជាថ្មី ក្នុងរយៈពេល ១០ ថ្ងៃក្រោយ។ ការអញ្ជើញប្រជុំលើកទី ២ នេះមិនត្រូវបានកំណត់កូរ៉ុមឡើយ។

ការសម្រេចរបស់សន្និបាត ដែលអាចយកជាការបាន គឺសំឡេងភាគច្រើនដាច់ខាតរបស់សមាជិកបានចូលរួម លើកលែងតែការសម្រេចលើថវិកាប្រចាំឆ្នាំរបស់សភាពាណិជ្ជកម្មកម្ពុជា។

**មាត្រា ១៧.–**

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ត្រូវចាត់មន្ត្រីជាន់ខ្ពស់មួយរូប ឱ្យធ្វើជាមន្ត្រីសម្របសម្រួលការងារជាមួយសភាពាណិជ្ជកម្មកម្ពុជា ។ មន្ត្រីសម្របសម្រួលរូបនេះ ត្រូវចូលរួមគ្រប់ការប្រជុំ និងសន្និបាតរបស់សភាពាណិជ្ជកម្មកម្ពុជាក្នុងឋានៈជាអ្នកពិគ្រោះយោបល់។

## ជំពូកទី ៤
## ហិរញ្ញប្បទាន

**មាត្រា ១៨.–**

ថវិការបស់សភាពាណិជ្ជកម្មកម្ពុជា ត្រូវបានអនុម័តដោយសន្និបាត តាមសំឡេងភាគច្រើន ២ ភាគ ៣ នៃសមាជិកចូលរួម។

**មាត្រា ១៩.–**

ថវិការបស់សភាពាណិជ្ជកម្មកម្ពុជា មានប្រភពមកពី៖

- វិភាគទានរបស់សមាជិក
- អំណោយឧបត្ថម្ភទាំងក្នុង និងក្រៅប្រទេស
- ចំណូលពីការគ្រប់គ្រងគ្រឹះស្ថានសាធារណៈ និងការដេញថ្លៃនានា
- ចំណូលព្រមទាំងវិភាគទានពីប្រភពផ្សេងៗ។

**មាត្រា ២០.-**

រាល់ការចំណាយត្រូវស្ថិតក្រោមការត្រួតពិនិត្យរបស់ហិរញ្ញិក និងដោយមានការយល់ព្រមពីប្រធានសភាពាណិជ្ជកម្មកម្ពុជា។

## ជំពូកទី ៥
## អវសានប្បញ្ញត្តិ

**មាត្រា ២១.–**

អនុក្រឹត្យលេខ ០៧ អនក្រ.បក ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់សភាពាណិជ្ជកម្មកម្ពុជា, អនុក្រឹត្យលេខ ២៩ អនក្រ.បក ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០០៩ ស្តីពីការកែសម្រួលមាត្រា៦

មាត្រា៩ និងមាត្រា១២ នៃអនុក្រឹត្យលេខ ០៧ អនក្រ.បក ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០៧ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់សភាពាណិជ្ជកម្មកម្ពុជា និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ២២.** –

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសភាពាណិជ្ជកម្មកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្ដីគោរពជម្រាបជូន

សម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ប៉ាន សូរស័ក្តិ**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ